**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**រដ្ឋបាលជលផល**

# សេចក្តីប្រកាសព័ត៌មាន

រដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសេចក្តីរីករាយនិងថ្លែងអំណរគុណ ចំពោះបងប្អូនប្រជាពលរដ្ឋ ពិសេសអ្នកនេសាទដែលបានចូលរួមលែងនូវប្រភេទត្រីកម្រ ត្រីមេពូជ និងវារីសត្វផ្សេងទៀត ជាអាទិ៍ ត្រីរាជ ត្រីគល់រាំង ត្រីក្រសក់ អណ្តើកហ្លួង អណ្តើកសមុទ្រ ផ្សោតសមុទ្រ ដែលជាសកម្មភាពដ៏ប្រពៃក្នុងការចូលរួមថែរក្សាការពារនូវធនធានជលផល និងទទួលបាននូវការអបអរសាទរយ៉ាងខ្លាំងពីមហាជន។

ដោយឡែកនាពេលថ្មីៗនេះ មានបងប្អូនខ្លះបានលែងត្រីដែលមានប្រភពពីក្រៅប្រទេស ចូលក្នុងដែនទឹកធម្មជាតិ សកម្មភាពនេះអាចនឹងបង្កហានិភ័យដល់មច្ឆជាតិក្នុងស្រុក។ វារីសត្វឬប្រភេទត្រីដែលមានប្រភពពីក្រៅប្រទេស មួយចំនួនជាប្រភេទកាច ស៊ីសាច់ជាអាហារ ឬសាយកូនលឿន ប្រសិនបើប្រភេទត្រីឬវារីសត្វទាំងនោះ មានវត្តមានកាន់តែច្រើននៅក្នុងដែនទឹកធម្មជាតិ វានឹងស៊ីត្រីក្នុងធម្មជាតិ ដណ្តើមទីជម្រក និងអាចនាំឱ្យប៉ះពាល់ដល់ពូជក្នុងស្រុក។ បញ្ហានេះរដ្ឋបាលជលផល សូមអំពាវនាវដល់បងប្អូនដែលកំពុងចិញ្ចឹមប្រភេទត្រីឬវារីសត្វមានប្រភពពីក្រៅប្រទេស សូមថែរក្សាឱ្យបានខ្ជាប់ខ្ជួន ចៀសវាងលែង ឬធ្វេសប្រហែសឱ្យរួចចូលក្នុងដែនទឹកធម្មជាតិ។ ករណីបងប្អូនមានបំណងលែងត្រីឬវារីសត្វមានប្រភពពីក្រៅប្រទេស សូមទំនាក់ទំនងមកមន្ត្រីជំនាញជលផល តាមលេខទូរស័ព្ទដូចខាងក្រោម។

រដ្ឋបាលជលផលសូមលើកទឹកចិត្តដល់បងប្អូនប្រជាពលរដ្ឋ ពិសេសអ្នកនេសាទបន្តផ្តល់ព័ត៌មានដល់សមត្ថកិច្ចជលផលនិងលែងនូវប្រភេទត្រីកម្រ ត្រីមេពូជ និងវារីសត្វផ្សេងទៀតដែលនេសាទបានឱ្យបានផុសផុលថែមទៀត ដែលនេះជាសកម្មភាពដ៏មានតម្លៃមិនអាចកាត់ថ្លៃបាន ក្នុងការចូលរួមថែរក្សា ការពារ និងអភិរក្សធនធានជលផលយើងឱ្យបានគង់វង្ស សម្រាប់កូនចៅជំនាន់ក្រោយ។

លេខទូរស័ព្ទទំនាក់ទំនង៖ **០១២ ៩០៨ ១២១, ០៩៩ ៧៩១ ៩១៩, ០១២ ៩១១ ៨១១។**

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៤




សកម្មភាពដែលទទួលបានការគាំទ្រនិងសាទរ




សកម្មភាពដែលត្រូវចៀសវាង មិនត្រូវឱ្យកើតមានតទៀត